00380157

D164/4/8

នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ២៤)

ដាក់ទៅ: អង្គបុរេជំនុំជម្រះ

ថ្ងៃដាក់: ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៩

ភាគីអ្នកដាក់: សហព្រះរាជអាជ្ញា

ភាសាដើម: អង់គ្លេស

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 28 / 09 / 2009
ម៉ោង (Time/Heure): 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ**

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 28 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [signature]

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ**

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញា ទៅលើសំណើរបស់ ខៀវ សំផន ដែលសុំឲ្យពិនិត្យឡើងវិញ ទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ អំពីសវនាការផ្ទាល់មាត់**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** |
| --- | --- |
| **ការិ.សហព្រះរាជអាជ្ញា៖** | **អង្គបុរេជំនុំជម្រះ៖** |
| លោកស្រី ជា លាង | ចៅក្រម ប្រាក់ គឹមសាន, ប្រធាន |
| លោក William SMITH | ចៅក្រម Rowan DOWNING, QC |

លោក យ៉េត ចរិយា
លោក សេង ប៊ុនឃាង
លោក Vincent de WILDE
លោក Anees AHMED
លោក Tarik ABDULHAK

ចៅក្រម ន័យ ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីជនត្រូវចោទ៖**
**នួន ជា**
លោក សុន អារុណ
លោក Michel PESTMAN
លោក Victor KOPPE

**លោក អៀង ធីរិទ្ធ**
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS

**ខៀវ សំផន**
លោក សរ សូវ៉ាន
លោក Jacques VERGES

# សេចក្តីសង្ខេប

១. នៅថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះ បានបង្គាប់ ("សេចក្តីបង្គាប់")[1] ឱ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបទៅនឹងសំណើ ("សំណើ")[2] សុំឱ្យមានការពិចារណាឡើងវិញ ធ្វើឡើងដោយដើមបណ្តឹងឧទ្ធរណ៍ ខៀវ សំផន ទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ("សេចក្តីសម្រេច")[3] ដែលបានបដិសេធសំណើសុំបើកសវនាការសួរដេញដោលផ្ទាល់មាត់ នៃបណ្តឹងឧទ្ធរណ៍នេះ[4] ។ សហព្រះរាជអាជ្ញា ដាក់សេចក្តីសង្កេតទាំងនេះ ដើម្បីជាការអនុវត្តន៍ទៅតាមសេចក្តីបង្គាប់នោះ ។

២. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គបុរេជំនុំជម្រះ បានធ្វើការសង្កេតដូចតទៅនេះ នៅក្នុងចំណោមបញ្ហាផ្សេងៗទៀត៖

"អង្គបុរេជំនុំជម្រះយល់ឃើញថា ជាវិធានទូទៅ អង្គបុរេជំនុំជម្រះពិចារណាអំពីប្រភេទពិសេស នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ ។ វិធីសាស្ត្រនេះកើតមាន ដោយសារតែប្រភេទសម្ងាត់នៃការស៊ើប

---

[1] *ករណីរបស់ ខៀវ សំផន,* សេចក្តីសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍ដែលដាក់ដោយ ខៀវ សំផន និងសេចក្តីបង្គាប់ដល់សហព្រះរាជអាជ្ញា, D164/4/7, ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩, កថាខណ្ឌទី១៥ [*ចាប់ពីនេះតទៅហៅថា* សេចក្តីបង្គាប់] ។

[2] *ករណីរបស់ ខៀវ សំផន,* សំណើសុំឱ្យពិនិត្យមើលឡើងវិញនូវ សេចក្តីសម្រេចទាក់ទងនឹង សំណើសុំឱ្យមានសវនាការដើម្បីពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ ២៤ និង ២៥, D164/4/6, ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០០៩ [*ចាប់ពីនេះតទៅហៅថា* សំណើ] ។

[3] *ករណីរបស់ ខៀវ សំផន,* សេចក្តីសម្រេចលើសំណើសុំបើកសវនាការសួរដេញដោលផ្ទាល់មាត់ លើបណ្តឹងឧទ្ធរណ៍ អបជ២៥ និង អបជ២៥, D164/4/3, ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩, ទំព័រទី៣ [*ចាប់ពីនេះតទៅហៅថា* សេចក្តីសម្រេច] ។

[4] *ករណីរបស់ ខៀវ សំផន,* បណ្តឹងឧទ្ធរណ៍រួមរបស់មេធាវីការពារក្តី ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ស្តីពីសំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ SMD, ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩, D164/4/1, ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ [*ចាប់ពីនេះតទៅហៅថា* បណ្តឹងឧទ្ធរណ៍] ។

អង្កេត ដូចមានចែងនៅក្នុងវិធាន៥៦ នៃវិធានផ្ទៃក្នុង ។ [...] ហេតុដូច្នេះ អង្គបុរេជំនុំជម្រះបដិសេធសំណើសុំបើកសវនាការ”[5] ។

៣. សហព្រះរាជអាជ្ញា បញ្ជាក់ម្តងទៀតថា នៅក្នុងកាលៈទេសៈនៃបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ មិនតម្រូវឱ្យមានសវនាការផ្ទាល់មាត់ទេ[6] ។ បញ្ហាដែលបានលើកឡើងគឺ “សាមញ្ញនិងមានលក្ខណៈបច្ចេកទេសសុទ្ធសាធ” ហេតុដូច្នេះហើយ បណ្តឹងឧទ្ធរណ៍នេះអាចត្រូវបានសម្រេចជាលាយលក្ខអក្សរតែឯងបាន[7] ។ អាស្រ័យហេតុដូច្នេះ អង្គបុរេជំនុំជម្រះ បានច្រានចោលយ៉ាងត្រឹមត្រូវនូវសំណើរបស់ដើមបណ្តឹងឧទ្ធរណ៍ ដែលសុំឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ ។

៤. ទោះជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញា សង្កេតឃើញថា គោលបំណងនៃវិធានផ្ទៃក្នុងមិនចាំបាច់កំណត់ថា រៀងរាល់បណ្តឹងឧទ្ធរណ៍ដែលបានលើកឡើងអំពីបញ្ហាសម្ងាត់ត្រូវតែបានធ្វើសេចក្តី សម្រេចជាលាយលក្ខអក្សរតែឯងនោះទេ ។ សវនាការផ្ទាល់មាត់ជាសម្ងាត់មួយអាចនឹងត្រូវបានចេញដីកា បើអង្គបុរេជំនុំជម្រះ ពិចារណាឃើញថាសវនាការសាធារណៈមួយអាចនឹងធ្វើឱ្យខូចខាតដល់កិច្ចស៊ើបសួរ ឬធ្វើឱ្យមានគ្រោះថ្នាក់ដល់ជនរងគ្រោះ ឬសាក្សី ។ អាស្រ័យហេតុដូច្នេះ វាមិនចាំបាច់ត្រូវធ្វើតាមថា រៀងរាល់បណ្តឹងឧទ្ធរណ៍សម្ងាត់ ត្រូវតែបានធ្វើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរតែឯងនោះទេ ។

## សំណើ

៥. ទន្ទឹមនេះ សហព្រះរាជអាជ្ញា សន្និដ្ឋានថា អង្គបុរេជំនុំជម្រះបដិសេធទៅលើសំណើសុំឱ្យមានសវនាការផ្ទាល់មាត់ ដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ។ ប៉ុន្តែ អាស្រ័យដោយ

---

[5] សេចក្តីសម្រេច, កថាខ័ណ្ឌទី៥ ។

[6] *ករណីរបស់ ខៀវ សំផន,* ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, នួន ជា, ខៀវ សំផន និងអៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធសំណើរួមរបស់មេធាវីការពារក្តី សុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ, D164/4/2, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩, កថាខ័ណ្ឌទី១២-១៦ [*ចាប់ពីនេះតទៅហៅថា* ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍] ។

[7] សេចក្តីសម្រេច, កថាខ័ណ្ឌទី៣ ។

00380161



បញ្ហាច្បាប់ អង្គបុរេជំនុំជម្រះ អាចពិចារណាឱ្យមានសវនាការផ្ទាល់មាត់ជាសម្ងាត់នានា សម្រាប់បណ្តឹងឧទ្ធរណ៍នាពេលអនាគតទាំងឡាយ ដែលអាចនឹងកើតចេញអំពីសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទាំងនោះ បើសិនជាស្ថានការណ៍តម្រូវឱ្យមានដូច្នេះ ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៩ | លោកស្រី ជា លាង<br>**សហព្រះរាជអាជ្ញា** | ភ្នំពេញ | |
| | លោក William SMITH<br>**សហព្រះរាជអាជ្ញារង្គទី** | ភ្នំពេញ | |